00871433

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

E202/46

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 20 / 12 / 2012
ម៉ោង (Time/Heure) : 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

**Case File/Dossier No. 002/19-09-2007/ECCC/TC**

ចំណាត់ថ្នាក់ឯកសារ៖ **សាធារណៈ**:

## ដីកាបង្គាប់ឲ្យនាំខ្លួន

យើងចៅក្រម **និល នន្ទ** ជាប្រធានអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ។

**យោង** "ដីកាកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២" (ឯកសារ E131) ដែលបានចេញដោយអង្គជំនុំជម្រះសាលាដំបូងនៅថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ។

មន្ទីរឃុំឃាំង អ.វ.ត.ក
លេខ 159 ម.ឃ
ថ្ងៃទី 20 ខែ ធ្នូ ឆ្នាំ 2012
ម៉ោង 10h45 នាទី

**<u>បង្គាប់មក</u>**

លោកប្រធានមន្ទីរឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឲ្យនាំខ្លួនជនជាប់ចោទឈ្មោះ៖

| | |
|---|---|
| នួន ជា | ភេទ ប្រុស កើតនៅថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩២៦ នៅភូមិ វត្តគរ ឃុំ វត្តគរ ស្រុក សង្កែ ខេត្ត បាត់ដំបង ប្រទេសកម្ពុជា |
| ខៀវ សំផន | ភេទ ប្រុស កើតនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ១៩៣១ នៅឃុំ រំចេក ស្រុក រំដួល ខេត្ត ស្វាយរៀង ប្រទេសកម្ពុជា |
| អៀង សារី (ឈ្មោះកំណើត គឹម ត្រាំង) | ភេទ ប្រុស កើតនៅថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩២៥ នៅឃុំ លឿងភាំ ស្រុក ត្រាវិញ ខេត្ត ត្រាវិញ វៀតណាមខាងត្បូង (កូសាំងស៊ីន) |

មកកាន់បន្ទប់សវនាការធំ (លើកលែងតែជនជាប់ចោទ អៀង សារី ត្រូវនាំខ្លួនមកកាន់បន្ទប់ឃុំខ្លួននៅខាងក្រោមបន្ទប់សវនាការ) នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា នៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១២ នៅម៉ោង ៨.៣០ នាទីព្រឹក ដើម្បីចូលរួមសវនាការលើអង្គសេចក្ដីនៃសំណុំរឿងលេខ ០០២ និងត្រូវនាំជនជាប់ចោទត្រឡប់ទៅមន្ទីរឃុំឃាំងវិញនៅពេលសវនាការត្រូវបានផ្អាក ឬបញ្ចប់។

ភ្នំពេញ ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២

ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន

00871435

០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ

E202/46

# <u>ការទទួលស្គាល់អំពីការទទួលលិខិត</u>

យើង [illegible] ជាប្រធានមន្ទីឃុំឃាំងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ពិតជាបានទទួលដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទមកចំពោះមុខអង្គជំនុំជម្រះសាលាដំបូងពិតប្រាកដមែន។ យើងនឹងចាត់បញ្ជូនឈ្មោះនេះឲ្យបានទាន់ពេលវេលា និងទៀងទាត់តាមកាលកំណត់របស់អង្គជំនុំជម្រះសាលាដំបូង។

ភ្នំពេញ ថ្ងៃទី 20 ខែ ធ្នូ ឆ្នាំ ២០១២

**ប្រធានមន្ទីឃុំឃាំង**

ដីកាបង្គាប់ឲ្យនាំខ្លួន/ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១២/សាធារណៈ